**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**ខុទ្ទកាល័យ**
ក្រុមការងារតាមដានការអនុវត្តគោលការណ៍ណែនាំ
របស់ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

លេខ ១៣១/២៥.ស.រ.......

## សូមគោរពជូន

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

## ជ្រាបជាព័ត៌មាន

| ល.រ | ឯកសារយោង | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | របាយការណ៍លេខ ០៧៨/២៥ រ.ប.ក. ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥ ដែលមានចំណារដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមអភិសន្តិបណ្ឌិត** ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៥ | ០១ ច្បាប់ | ដើម្បីជូនជ្រាប និងអនុវត្ត |
| | **សរុប** | ០១ ច្បាប់ | |

ថ្ងៃសុក្រ ៦ រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៥
**ប្រធានក្រុមការងារ**

**បណ្ឌិត ទូច សុឃៈ**

សូមគោរពស្នើសុំការឆ្លើយតបព័ត៌មាន
តាមរយៈលេខទូរសព្ទ៖
លោក រឿន ភារុន ០១៧ ៦៩៩ ៩៨៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
ខុទ្ទកាល័យ
ក្រុមការងារតាមដានការអនុវត្តគោលការណ៍ណែនាំ
របស់ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

លេខ: ០៧[illegible]/២៥ [illegible]

**សូមគោរពជូន**
**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** (គ.ជ.ប.ជ.)

ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ចូល លេខ: 422
ថ្ងៃ 03.4.25 ម៉ោង:
បញ្ជូន:

**កម្មវត្ថុ៖** របាយការណ៍ស្តីពីសម្រង់គោលការណ៍ណែនាំរបស់ **ឯកឧត្តមអភិសន្តិបណ្ឌិត** នៅក្នុងកម្មវិធីផ្សព្វផ្សាយរបាយការណ៍ជាតិ បូកសរុបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមអភិសន្តិបណ្ឌិត** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ក្នុងកម្មវិធីផ្សព្វផ្សាយរបាយការណ៍ជាតិ បូកសរុបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ ដែលបានប្រព្រឹត្តឡើងនៅក្នុងសាលប្រជុំ S ទីស្តីការក្រសួងមហាផ្ទៃ នាព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥ **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានផ្តល់គោលការណ៍ណែនាំ ដើម្បីតម្រង់ទិសការងារចំនួន ១៣ ចំណុច រួមមាន៖

១- **គ្រប់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ អង្គទូត អង្គការ និងសមាគម** ត្រូវយកចិត្តដាក់ចូលរួមសហការជួយទប់ស្កាត់ប្រឆាំងគ្រឿងញៀនទាំងអស់គ្នា។ កុំគិតថា ការងារនេះរបស់ខ្ញុំ ការងារនេះរបស់គេ។ ដូច្នេះ ត្រូវចាត់វិធានការរួមគ្នា សហការគ្នាធ្វើការឱ្យមានប្រសិទ្ធភាពទាំងអស់គ្នា។ ដូចទ្រឹស្តីពោលថា មិនថា ឆ្មាសឆ្មាខ្មៅ ឱ្យតែចាប់កណ្តុរបាន គឺជាឆ្មាល្អហើយ។

២- **លោកជំទាវ ជូ ប៊ុនអេង** ត្រូវពិនិត្យឡើងវិញអំពីទិន្នន័យ សូចនាករ និងបញ្ហាដែលមានក្នុងដៃស្រាប់ ដើម្បីចាត់វិធានការវាយឱ្យចំ និងដោះស្រាយឱ្យខាងតែបាន ដូច្នេះត្រូវប្រែក្លាយពីបញ្ហាទិន្នន័យដុំថ្ម ឱ្យក្លាយជាទិន្នន័យដុំពេជ្រ។

៣- **បណ្ឌិត្យសភានគរបាលកម្ពុជា** សហការជាមួយឯកឧត្តមបណ្ឌិត **ទូច វិសាលសុខ និងលោកជំទាវ ជូ ប៊ុនអេង** ត្រូវរៀបចំបញ្ចូលកម្មវិធីអប់រំ និងផ្សព្វផ្សាយអំពីការជួញដូរមនុស្ស និងគ្រឿងញៀនដល់សិស្ស និស្សិតមន្ត្រីនគរបាល រយៈពេលមួយទៅពីរម៉ោងក្នុងមួយសប្តាហ៍ ដើម្បីឱ្យពួកគេបានជ្រួតជ្រាបយល់ដឹង និងអាចចូលរួមដោះស្រាយបញ្ហាបាន។

៤- **លោកជំទាវ ជូ ប៊ុនអេង និងអង្គការ Caritas កម្ពុជា** ត្រូវសហការរៀបចំចងក្រងមេរៀនបទពិសោធន៍ការងារល្អៗពីកម្ពុជាដែលបានអនុវត្ត កន្លងទៅ ដើម្បីផ្សព្វផ្សាយព័ត៌មានរូបភាពវិជ្ជមានពីកម្ពុជាដល់ភាគីអន្តរជាតិឱ្យទូលំទូលាយ។ កុំឱ្យបរទេសចោទប្រកាន់ថា អាជ្ញាធរកម្ពុជាមិនបានចាត់វិធានការប្រឆាំងការជួញដូរមនុស្សសោះ។

៥- **លោកជំទាវ ជូ ប៊ុនអេង** ត្រូវបន្តវិនិយោគលើបច្ចេកវិទ្យាឌីជីថលដែលមានស្រាប់ ដើម្បីគ្រប់គ្រងការងារឱ្យមានប្រសិទ្ធភាព និងលឿនរហ័ស។

៦- ស្នើឱ្យ **គ្រប់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ** ត្រូវបន្តពង្រឹងបន្ថែមទៀតនូវសមត្ថភាព និងរបៀបរបបការងារ ដល់មន្ត្រីក្រោមឱវាទ តាមខ្សែបណ្តោយរបស់ខ្លួន ពិសេសមន្ត្រីដែលទទួលការចាត់តាំងថ្មី ដោយសហការជាមួយនឹងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. ដើម្បីសម្របសម្រួលផ្តល់វគ្គបណ្តុះបណ្តាលបន្ថែមទៀត អំពីតួនាទីនិងភារកិច្ច ការទទួលខុសត្រូវតាមវិស័យក្នុងការងារប្រឆាំងការជួញដូរមនុស្ស ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

៧- ស្នើឱ្យ **អភិបាលខេត្តតាមព្រំដែន** ត្រូវរៀបចំបញ្ចូលរបៀបវារៈប្រជុំស្តីពីការជួញដូរមនុស្ស និងគ្រឿងញៀន ឱ្យបានយ៉ាងតិចចំនួន ៣ ឬ៤ដងក្នុងមួយឆ្នាំ ដើម្បីបង្ហាញឆន្ទៈខ្ពស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទប់ស្កាត់ការជួញដូរមនុស្សតាមព្រំដែន ជាពិសេសការជួញដូរមនុស្សនៅក្នុងកាស៊ីណូតាមព្រំដែន។

៨- ស្នើឱ្យ **លោកជំទាវ ជូ ប៊ុនអេង និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ.** ត្រូវអនុវត្តតាមផែនការដែលបានដាក់ចេញឱ្យមានប្រសិទ្ធភាព ដោយប្រើប្រាស់ធនធានដែលមានស្រាប់ គួបផ្សំនឹងធនធានដែលចូលរួមពីបណ្តាដៃគូនានា និងអាចចលនាការចូលរួមបន្ថែមទៀតពីវិស័យឯកជន ដើម្បីងាយស្រួលក្នុងការអនុវត្ត ពិសេសចលនាការចូលរួមក្នុងសកម្មភាពបង្ការទប់ស្កាត់ផ្តោតលើការយល់ដឹងឈានទៅរកការផ្លាស់ប្តូរទស្សនៈ និងឥរិយាបទអំពីអំពើជួញដូរមនុស្ស។

៩- ស្នើឱ្យ **រដ្ឋបាលរាជធានី-ខេត្តទាំង២៥** ណែនាំឱ្យពិធីករ និងពិធីការិនីជួយផ្សព្វផ្សាយអំពីការប្រឆាំងការជួញដូរមនុស្សគ្រប់ទម្រង់ នៅតាមព្រឹត្តិការណ៍សង្រ្គាន្តរាជធានី-ខេត្តទូទាំងប្រទេស ដើម្បីយុវជន និងសាធារណជនបានជ្រួតជ្រាប។

១០- ស្នើឱ្យ **រដ្ឋបាលខេត្តជាប់ព្រំដែនទាំងអស់ ជាពិសេសព្រំដែនថៃ** ពិនិត្យអប់រំណែនាំឱ្យប្រជាពលរដ្ឋបំពេញបែបបទឆ្លងដែនដោយស្របច្បាប់ ជាពិសេសប្រជាពលរដ្ឋចំណាកស្រុកខុសច្បាប់ ដើម្បីធានាការរៀបចំគ្រប់គ្រងប្រជាពលរដ្ឋចេញ-ចូលស្របច្បាប់។

១១- ស្នើឱ្យ **ក្រសួង ស្ថាប័ន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. និងអង្គភាពពាក់ព័ន្ធ** ត្រូវតាមដាន និងវាយតម្លៃលើការអនុវត្ត និងលទ្ធផលការងារជាប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និងធ្វើរបាយការណ៍ឱ្យបានទៀងទាត់។

១២- ស្នើឱ្យ **ក្រសួង ស្ថាប័ន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. និងអង្គភាពពាក់ព័ន្ធ** ត្រូវពង្រឹងការអនុវត្តវិធានការតាមដានសភាពការណ៍ស្តីពី លំហូរនៃការធ្វើចំណាកស្រុកតាំងពី

មូលដ្ឋានភូមិ ឃុំ សង្កាត់ រហូតដល់ការឆ្លងកាត់ព្រំដែនទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ព្រមទាំងប៉ាន់ប្រមាណអំពីគោលដៅនៃបទល្មើសឱ្យបានជាក់លាក់ ដើម្បីទប់ស្កាត់ភាពរងគ្រោះ ឱ្យបានទាន់ពេលវេលា។

១៣ - ស្នើឱ្យ **ក្រសួង ស្ថាប័ន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. និងអង្គភាពពាក់ព័ន្ធ** ត្រូវបន្តពង្រឹងកិច្ចសហការជាមួយប្រទេសជិតខាង និងប្រទេសពាក់ព័ន្ធតាមកិច្ចព្រមព្រៀង ឬអនុស្សរណៈដែលមានស្រាប់ ឬបង្កើតឱ្យមានជាមួយបណ្តាប្រទេសដែលពាក់ព័ន្ធ ជាពិសេស **អូស្ត្រាលី និងចិន** ដើម្បីងាយស្រួលក្នុងការពង្រឹងកិច្ចសហការក្នុងការបង្ការ បង្ក្រាប សង្គ្រោះបន្ទាន់ ផ្តន្ទាទោសជនល្មើស និងគាំពារជនរងគ្រោះតាមផ្លូវច្បាប់។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបជាបរាយការណ៍ និងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអភិសន្តិបណ្ឌិត** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ៕

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥
**លេខាធិការ**

រឿន តារុន

បានពិនិត្យនិងសូមគោរពជូន
**ឯកឧត្តមអភិសន្តិបណ្ឌិត** មេត្តាជ្រាបជាបរាយការណ៍
និងផ្តល់គោលការណ៍ណែនាំដ៏ខ្ពង់ខ្ពស់។
ថ្ងៃព្រហស្បតិ៍ ១៤រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥
**ប្រធានក្រុមការងារ**

បណ្ឌិត ទូច សុឃះ